# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ ១៤៨ អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ បន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧ /០៣៥, ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០៤ អនក្រ.បក, ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨
- បានឃើញប្រកាសលេខ ១៤៤៨ សហវ.ប្រក , ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ ។
- បានឃើញប្រកាសលេខ ១៤៥០ សហវ.ថហ, ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបែងចែកចំណាយ ឥណទានថវិកាផ្ទៃក្នុងជំពូក គណនី អនុគណនី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨
- លិខិតលេខ ៣៣៨៩ អយក.ហវ , ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៨ របស់ក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាតាមកម្មវិធីចំនួន ៨.០៩៣.០៩២.០០០រៀល ( ប្រាំបីពាន់កៅសិបបីលានកៅសិបពីរពាន់រៀលគត់ ) ក្នុងនោះ ផ្នែកអប់រំ ចេញពីជំពូក ៦០ ( ការទិញ) ចំនួន ៤.៦៨៧.៧២៥.០០០រៀល ( បួនពាន់ប្រាំមួយរយប៉ែតសិបប្រាំពីរលានប្រាំពីររយម្ភៃប្រាំពាន់រៀលគត់), ជំពូក៦១ ( សេវាខាងក្រៅ) ចំនួន ២៤០.១២៦.០០០រៀល (ពីររយសែសិបលានមួយរយម្ភៃប្រាំមួយពាន់រៀលគត់), ជំពូក៦២( សេវាខាងក្រៅផ្សេងៗ) ចំនួន ២.៤៩៨.១៣៨.០០០ រៀល(ពីរពាន់បួនរយប្រាំកៅសិបប្រាំបីលានមួយរយសាមសិបប្រាំបីពាន់រៀលគត់) និង ជំពូក៦៥ (ឧបត្ថម្ភកធន និង ជំនួយសង្គម) ចំនួន ៥១៣.២០០.០០០រៀល( ប្រាំរយដប់បីលានពីររយពាន់រៀលគត់) ។ ផ្នែកឧត្តមសិក្សា ជំពូក៦២ ( សេវាខាងក្រៅផ្សេងៗ) ចំនួន ២០.៤៨៨.០០០រៀល( ម្ភៃលានបួនរយប៉ែតសិបប្រាំបីពាន់រៀលគត់) និង ជំពូក៦៥ (ឧបត្ថម្ភកធន និង ជំនួយសង្គម) ចំនួន ៣០.៧៤៥.០០០រៀល( សាមសិបលានប្រាំពីររយសែសិបប្រាំពាន់រៀលគត់) ។ ផ្នែកយុវជន និង កីឡា ជំពូក៦០ ( ការទិញ) ចំនួន ៧៧០.០០០រៀល ( ប្រាំពីររយចិតសិបពាន់រៀលគត់), ជំពូក៦១ ( សេវាខាង ក្រៅ) ចំនួន ៥.៤០០.០០០រៀលគត់ ( ប្រាំលានបួនរយពាន់រៀលគត់), ជំពូក៦២ ( សេវាខាងក្រៅផ្សេងៗ) ចំនួន ៥២.៧០០.០០០រៀល ( ហាសិបពីរលានប្រាំពីររយពាន់រៀលគត់), និង ជំពូក៦៥ ( ឧបត្ថម្ភ កធន និង ជំនួយសង្គម) ចំនួន ៤៣.៨០០.០០០រៀល( សែសិបបីលានប្រាំបីរយពាន់រៀលគត់) មកជំពូក៦១ ( សេវាខាងក្រៅ) ថវិកាមិនមែនកម្មវិធី ផ្នែកឧត្តមសិក្សា សំរាប់ទូទាត់ជូនសហគ្រាស សំណង់ ដួង ហេង ដែលបានជួសជុលអាគារ សិក្សា "ខ" និង ក្រុមហ៊ុនលី ឈួង សំណង់អាហារ័ណនីហារ័ណ សាងសង់អាគារមួយខ្នងមានកំពស់៤ជាន់ នៅវិទ្យាស្ថាន បច្ចេកវិទ្យាកម្ពុជា ។

**មាត្រា២:** ការបែងចែកឥណទានចំណាយថវិកាផ្ទេក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំពេញតំរូវការចំណាយជាក់ស្តែង របស់ក្រសួងអប់រំ យុវជន និង កីឡា សំរាប់ការ គ្រប់គ្រងឆ្នាំ ២០០៨ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវទទួល បន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ